# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ អំពីអ្នកមានអំណាចខ្មែរប្រើអំពើហិង្សាមកលើប្រជាពលរដ្ឋរបស់ខ្លួន

web site: hoksavann.org

ថ្ងៃទី៦ មេសា ២០០៥

និយាយតាមពាក្យសាមញ្ញ មនុស្សដែលគេឲ្យធ្វើជាមេគេ គឺមនុស្សដែលមានលក្ខណៈគ្រាន់បើជាងគេ  មានសមត្ថភាពមានគុណធម៌គួរគោរព ចេះរួមសុខរួមទុក្ខជាមួយមនុស្សដែលខ្លួនគ្រប់គ្រង ។ មនុស្សដែលមិនពោលលើកតម្កើងខ្លួនឯង បន្ទុះបង្អាប់អ្នកដទៃមិនគិតតែប្រយោជន៍ខ្លួននិងបក្សពួកខ្លួន តែគិតប្រយោជន៍រួមឬប្រយោជន៍ជាតិជាអាទិភាព ។ ព្រះសម្ពុទ្ធមានចរិយា៣យ៉ាងសំរាប់ផ្តល់ប្រយោជន៍ឲ្យមនុស្សពពួក គឺចំពោះខ្លួនព្រះអង្គផ្ទាល់ដោយសាងព្រះអង្គឲ្យបានត្រាស់ជាព្រះពុទ្ធ (ពុទ្ធត្ថចរិយា) និងសង្រ្គោះលោកទាំងមូល (លោកត្ថចរិយា) ។ ដើម្បីសង្រ្គោះមនុស្សសត្វទូទៅ ឲ្យចេញចាកទុក្ខបានដោយវិធីបង្ហាញផ្លូវប្រតិបត្តិតាមរយៈការសំដែងធម៌ទេសនា លុះត្រាតែព្រះអង្គបានត្រាស់ជាព្រះពុទ្ធមានសមត្ថភាពគ្រប់គ្រាន់ជាមុនសិន ។ ការសង្រ្គោះព្រះញាតិមានព្រះមាតាបិតាជាដើម ដើម្បីបំពេញកិច្ចដែលជនទាំងនោះធ្លាប់មានគុណចំពោះព្រះអង្គ ។ បេសកកម្មជាគោលបំណងសំខាន់របស់ព្រះអង្គ គឺការសំដែងធម៌ទេសនាប្រោសមនុស្សសត្វដែលកំពុងវិលកើតវិលស្លាប់ក្នុងវដ្តសង្សារដាក់ដល់ត្រើយ គឺព្រះនិព្វានរួចផុតទុក្ខភ័យ ព្រះអង្គក្រាលព្រះទ័យអាណិតអាសូរមនុស្សសត្វ ប្រកបដោយមេត្តាករុណាឥតព្រំដែន (អប្បមញ្ញាព្រហ្មវិហារ) ។ ក្រឡេកមើលចរិតអ្នកដឹកនាំខ្មែរស្ទើរគ្រប់ជំនាន់រហូតដល់បច្ចុប្បន្ននេះ ដណ្តើមអំណាចគ្នា ពឹងបរទេសឲ្យកំទេចគូប្រជែងរបស់ខ្លួន ពេលមានជ័យជំនះកាត់ដីជាតិឲ្យគេដើម្បីតបគុណ ។ មើលងាយប្រជាពលរដ្ឋរបស់ខ្លួន រហូតវាយប្រហារកាប់សម្លាប់ចំពោះប្រជាពលរដ្ឋណា ដែលហ៊ានក្រោកឡើងទាមទាររកយុត្តិធម៌ ។ ទុកប្រជាពលរដ្ឋគ្រាន់តែជារូបតុក្កតាចាំតែធ្វើតាមអ្នកដឹកនាំប៉ុណ្ណោះ សូមទាញឧទាហរណ៍ខ្លះក្នុងបញ្ហានេះទុកជាសក្ខីភាព ។

★ អំណាចខ្មែរក្រហមជាអំណាចព្រះអាទិទេព ដែលព្រះប្រទានឲ្យចង់កាប់សម្លាប់ប្រជាពលរដ្ឋណា បានតាមចិត្តគ្មានអំណាចតវ៉ាត្រូវតែសុខចិត្តស្លាប់ ។ និយាយម្យ៉ាងទៀត ជាយមរាជមានអំណាចលើភពទាំងបី អ្នកណាកើតអ្នកនោះត្រូវតែស្លាប់ដោយកណ្តាប់ដៃព្រះបាទយមរាជ ឬព្រះបាទមច្ចុរាជ មិនបាច់និយាយពីប្រជាធិបតេយ្យនិងយុត្តិធម៌អ្វីឡើយ។

★ ឆ្នាំ១៩៩៨ គេបញ្ជាឲ្យបាញ់ព្រះសង្ឃនិងក្រុមបាតុករដទៃទៀតមានចំនួនរាប់សែននាក់ ដែលហ៊ានក្រោកឡើងទាមទាររកយុត្តិធម៌ក្នុងការបោះឆ្នោតពុំត្រឹមត្រូវ ។ ព្រះសង្ឃជាច្រើនអង្គត្រូវសុគតនិងបាតុករដទៃទៀតត្រូវស្លាប់ដូចខ្មោចឆ្កែឆ្មា ។ អ្នកណាហ៊ានប្រឆាំងអ្នកនោះត្រូវតែស្លាប់ ទោះបីដឹងអ្នកបញ្ជានិងមេឃាតករក៏គ្មានធ្វើអ្វីគេកើតឡើយ ព្រោះតុលាការស្ថិតនៅក្រោមឥទ្ធិពលនៃអ្នកកាន់អំណាច បើអ្នកណាហ៊ានចោទគេថាជាឃាតករ គេនឹងចោទតបវិញថាបរិហារកេរ្តិ៍ ។ ដូច្នេះអ្នករងគ្រោះត្រូវស្លាប់ ហើយបើអ្នកណាហ៊ានថា គេសម្លាប់ត្រូវមានទោសទៀត ។

★ ក្រុមនិស្សិតទោះបីនៅក្មេងជាវ័យកំពុងសិក្សា ប៉ុន្តែជិតជាប់ក្នុងចិត្ត នូវគំនិតស្នេហាជាតិស្នេហាទឹកដីរបស់ខ្លួន ខំបញ្ចេញមតិតាមរយៈការធ្វើបាតុកម្មដើម្បីការពារទឹកដី ដែលបរទេសរំលោភយកបានត្រូវប៉ូលិសនិងកងអាវុធហត្ថចាប់ហែកបដាវាយដំច្រំធាក់យ៉ាងហារ ។ ទោះបីដឹងថាខ្លួននឹងត្រូវទារុណកម្មពីរដ្ឋអំណាច ព្រោះច្បាប់ធ្វើបាតុកម្មបញ្ចេញមតិត្រូវគេហាមក៏ដោយ ក៏ក្រុមនិស្សិតនៅតែព្យាយាមធ្វើ សុខចិត្តស្លាប់កុំឲ្យតែបាត់បង់ទឹកដី ។ ក្រៅពីក្រុមប៉ូលិស គេបង្កើតមនុស្សមួយក្រុមដែលជ្រើសរើសពីក្រុមក្មេងខ្វះការអប់រំគ្មានសីលធម៌ឲ្យឈ្មោះថាសមាគមក្មេងវត្ត ឲ្យវាយធ្វើបាបបំបាក់ស្មារតីនិស្សិតស្នេហាជាតិ ធ្វើការបន្លំជួសមុខប៉ូលិស ។ តាមការសង្កេតតាំងពីអភិបាលក្រុងភ្នំពេញឡើងកាន់តំណែងថ្មី មកសិទ្ធិបញ្ចេញមតិតាមរយៈការធ្វើបាតុកម្មនិងកូដកម្ម ព្រមទាំងការប្រជុំពិភាក្សាផ្សេងៗត្រូវបិទជិតឈឹងតែម្តង ទំនងជាធ្វើតាមបញ្ជាថ្នាក់លើ ឯប៉ូលិសនិងកងអាវុធហត្ថ ឃើញតែដើរបង្ក្រាបបាតុកម្មអហឹង្សាដោយអំពើហឹង្សាវាយដំទាត់ធាក់ លើកបោះលើឡាន គម្រាមឲ្យចុះហត្ថលេខា និងផ្តិតមេដៃឲ្យប្តេជ្ញាឈប់ធ្វើបាតុកម្មតទៅថ្ងៃមុខទៀត ។ អាជ្ញាធរខ្មែរមិនរវល់នឹងការថ្កោលទោសនូវទំរើរបស់ខ្លួន អំពីសំណាក់អង្គការសហប្រជាជាតិ និងអង្គការសិទ្ធិមនុស្សនានា ថាជាអំពើរំលោភសិទ្ធិមនុស្ស រំលោភរដ្ឋធម្មនុញ្ញខ្មែរបច្ចុប្បន្ន និងរំលោភលើអនុសញ្ញានានាដែលខ្លួនបានចុះហត្ថលេខា ។ អាជ្ញាធរក្រុងភ្នំពេញបានបំពានលើមុខងាររបស់ខ្លួន ដែលត្រូវរក្សាការពារនូវរាល់សកម្មភាពរបស់ប្រជាពលរដ្ឋ ក្នុងការបញ្ចេញមតិមានការធ្វើបាតុកម្មជាដើម ផ្ទុយទៅវិញ គេបែរជាប្រើច្បាប់ម្រែកលើប្រជាពលរដ្ឋរបស់ខ្លួនទៅវិញ ។

★ បញ្ហាដណ្តើមដីគ្នានៅប្រទេសកម្ពុជា ជាបញ្ហាក្តៅគគុក អ្នកក្រខ្សត់ឥតបុណ្យស័ក្តិមិនដែលក្តីឈ្នះអ្នកមានអំណាចឡើយ ថែមទាំងបានទទួលការគំរាមកំហែង រហូតបាញ់សម្លាប់ប្រជាពលរដ្ឋថែមទៀតផង ។ ដូចប្រជាពលរដ្ឋនៅភូមិក្បាលស្ពាន ឃុំប៉ោយប៉ែត ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យចំនួន២១៨គ្រួសារ បានត្រូវប៉ូលិសដែលអនុវត្តសាលក្រមបាញ់សម្លាប់ប្រជាពលរដ្ឋអស់ចំនួន៦នាក់ និងត្រូវរបួសជាច្រើននាក់ទៀត ។ អំពើឧក្រិដ្ឋនេះ បានត្រូវផ្តន្ទាទោសអំពីមតិជាតិនិងមតិអន្តរជាតិ ។ អំពើដ៏សាហាវជាច្រើន ដែលអ្នកមានអំណាចបាញ់សម្លាប់ប្រជាពលរដ្ឋមិនបានត្រូវយកមកកាត់ទោសឡើយ ។

★ អ្នកជាប់គុកនៅត្រពាំងខ្លុង ស្រុកពញាឮ ខេត្តកំពង់ចាម បានត្រូវប៉ូលិសបាញ់សម្លាប់អស់ជិត២០នាក់ ។ តាមច្បាប់អន្តរជាតិទោះបីអ្នកទោសលួចរត់ដោយដៃទទេ គ្មានអាវុធបាញ់គម្រាមមកប៉ូលិសទេ ប៉ូលិសគ្រាន់តែចេញចាប់មិនត្រូវបាញ់អ្នកទោសនោះឡើយ ។ បើប្រព្រឹត្តខុសច្បាប់ ប៉ូលិសអ្នកបាញ់នោះនឹងត្រូវមានទោសក្នុងបទធ្វើមនុស្សឃាត និងធ្វើឲ្យរបួសស្នាម ។ ប៉ុន្តែនៅប្រទេសកម្ពុជា ពុំមានអនុវត្តច្បាប់ឲ្យបានត្រឹមត្រូវឡើយ ជាពិសេសអ្នកមានអំណាចតែងតែរួចចាកទោស ។ អ្នកមានអំណាចពុំបានរៀនច្បាប់ឲ្យបានចេះដឹងច្បាស់លាស់ ហើយច្រើនប្រើកំហឹងពុំមានមេត្តាករុណាដល់មនុស្សជាតិ ហើយពុំបានគិតថា បើខ្លួនប្រព្រឹត្តអំពើហឹង្សាដូច្នេះទៅនឹងធ្វើឲ្យសង្គមរបស់ខ្លួនវិនាសអន្តរាយប្រជាពលរដ្ឋរស់នៅដោយការភ័យខ្លាច ។៚